# សេចក្តីប្រកាសសិទ្ធិឯកត្តជននៃ ការថែទាំសុខភាពតាមផ្ទះនៅរដ្ឋមីនណេសូតា (Minnesota Home Care)

### ក្នុងមួយច្បាប់លក្ខន្តិកៈនៃរដ្ឋ MINNESOTA ផ្នែកទី 144A.44 ។

### សិទ្ធិទាំងនេះត្រូវផ្តល់ឲ្យតែអតិថិជនដែលទទួលបាន ការថែទាំនៅផ្ទះ ពីអ្នកថែទាំនៅផ្ទះដែលមានការអនុញ្ញាតប៉ុណ្ណោះ ។

## សេចក្តីថ្លែងការស្តីពីសិទ្ធិ

បុគ្គលដែលទទួលបានសេវាថែទាំនៅផ្ទះ ទទួលបានសិទ្ធិដូចតទៅ៖

1. សិទ្ធិក្នុងការទទួលបាននូវព័ត៌មានជាលាយលក្ខណ៍អក្សរស្តីពីសិទ្ធិនានាមុនការទទួលបានសេវា ដោយរួមបញ្ចូលទាំងវិធានការ ដែលត្រូវធ្វើប្រសិនបើមានការរំលោភលើសិទ្ធិទាំងនោះ ។

2. សិទ្ធិក្នុងការទទួលបានការថែទាំ និងទទួលបានសេវាដោយយោងទៅតាមគម្រោងដ៏សមរម្យ និងដែលស្របតាមបច្ចុប្បន្នភាព ព្រមទាំងសិទ្ធិក្នុងការទទួលយកនូវការថែទាំសុខភាព កម្រិតស្តង់ដានៃការព្យាបាល ឬការថែទាំអ្នកជម្ងឺ ដើម្បីចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍ កែប្រែ និងការវាយតម្លៃចំពោះគម្រោង និងសេវាកម្មនានា ។

3. សិទ្ធិក្នុងការទទួលបានការជម្រាបជូនដំណឹងមុននឹងទទួលសេវា ប្រភេទ និងរបៀបវិធីរបស់បុគ្គលិកដែលនឹងត្រូវផ្តល់សេវា ភាពញឹកញាប់នៃការធ្វើសំណើរដើម្បីទៅពិនិត្យមើល ជម្រើសផ្សេងទៀតដែលអាចផ្តល់ជូនសម្រាប់ដោះស្រាយចំពោះតម្រូវការថែទាំនៅផ្ទះ ក៏ដូចជាផលវិបាកដែលអាចកើតឡើងចំពោះការបដិសេធទៅនឹងសេវាទាំងអស់នេះ ។

4. សិទ្ធិក្នុងការទទួលបានការជម្រាបជូនដំណឹងជាមុនស្តីពីការតម្រូវឲ្យមានការផ្លាស់ប្តូរណាមួយដោយភាគីផ្តល់សេវានៅក្នុងគម្រោងសេវា និងដើម្បីចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សាអំពីការផ្លាស់ប្តូរចំពោះគម្រោងសេវាទាំងនោះ ។

5. សិទ្ធិក្នុងការបដិសេធចំពោះសេវាកម្ម ឬការព្យាបាល ។

6. សិទ្ធិក្នុងការដឹង មុននឹងទទួលសេវាកម្ម ឬកំឡុងពេលចាប់ផ្តើមទៅសួរសុខទុក្ខ ក៏ដូចជាកម្រិតនៃសេវាដែលអាចផ្តល់ជូនបានដោយភាគីផ្តល់សេវាថែទាំដល់ផ្ទះ ។

7. សិទ្ធិក្នុងការទទួលបានការជម្រាបជូនដំណឹងមុនគឺជាអ្វីដែលអ្នកផ្តល់សេវាត្រូវគិតថ្លៃសម្រាប់សេវាកម្មនានា ទៅលើអ្វីដែលពន្យាការបង់ថ្លៃដែលអាចត្រូវបានគេរំពឹងទុកពីការធានារ៉ាប់រងសុខភាព កម្មវិធីសាធារណៈ ឬទៅលើប្រភពផ្សេងទៀតប្រសិនបើបានដឹង ក៏ដូចជាតើការគិតថ្លៃអ្វីខ្លះដែលអតិថិជនត្រូវទទួលខុសត្រូវបង់ថ្លៃ ។

8. សិទ្ធិក្នុងការដឹងថាអាចនឹងមានសេវាកម្មនានាដែលមាននៅក្នុងសហគមន៍, ដោយរួមមានភាគីផ្តល់សេវា និងសេវាថែទាំដល់ផ្ទះ ព្រមទាំងសិទ្ធិក្នុងការដឹងអំពីកន្លែងដែលអាចស្វែងរកព័ត៌មានអំពីសេវាកម្មទាំងនេះផងដែរ ។

9. សិទ្ធិក្នុងការជ្រើសរើសដោយសេរីក្នុងចំណោមបណ្តាភាគីផ្តល់សេវា ក៏ដូចជាសិទ្ធិក្នុងការផ្លាស់ប្តូរអ្នកផ្តល់សេវាបន្ទាប់ពីការចាប់ផ្តើមផ្តល់សេវា ដែលស្ថិតក្នុងដែននៃការធានារ៉ាប់រងសុខភាព ការធានារ៉ាប់រងការថែទាំរយៈពេលយូរអង្វែង ជំនួយផ្នែកវេជ្ជសាស្ត្រ ឬកម្មវិធីថែទាំសុខភាពផ្សេងទៀត ។

10. សិទ្ធិក្នុងការទទួលបានការរក្សាការសម្ងាត់ជាលក្ខណៈឯកជនចំពោះព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានផ្នែកហិរញ្ញវត្ថុ និងព័ត៌មានផ្នែកវេជ្ជសាស្ត្រ ព្រមទាំងសិទ្ធិក្នុងការទទួលបានការផ្តល់យោបល់ស្តីពីលក្ខន្តិកៈនិងនីតិវិធីរបស់អ្នកផ្តល់សេវា ចំពោះព័ត៌មានដែលប្រកាសឲ្យដឹងទាំងនោះ ។

11. សិទ្ធិក្នុងការចូលទៅប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន និងព័ត៌មានជាលាយលក្ខណ៍អក្សរចេញពីព័ត៌មានទាំងនោះដោយអនុលោមទៅតាមផ្នែក 144.291 រហូតដល់ 144.298 ។

12. សិទ្ធិក្នុងការទទួលបានការបម្រើដោយបុគ្គលដែលទទួលបានការហ្វឹកហាត់ត្រឹមត្រូវ ហើយដែលមានសមត្ថភាពក្នុងការបំពេញមុខងារក្នុងតួនាទីរបស់ខ្លួន ។

13. សិទ្ធិក្នុងការទទួលបានការព្យាបាលដោយត្រឹមត្រូវ ដោយគួរសម និងមានសិទ្ធិទទួលបានការព្យាបាលអ្នកជម្ងឺប្រកបដោយសីលធម៌វិជ្ជាជីវៈ ។

14. សិទ្ធិក្នុងការរួចផុតពីការរំលោភផ្លូវកាយ និងការប្រមាថពាក្យសម្តី, ការធ្វេសប្រហែស ការកេងប្រវ័ញ្ចផ្នែកហិរញ្ញវត្ថុ និងគ្រប់ទម្រង់នៃការធ្វើទុក្ខទោសដែលស្ថិតនៅក្នុងវង្វង់ច្បាប់ស្តីពីការធ្វើទុក្ខទោសដល់នីតិជន និងច្បាប់ស្តីពីការធ្វើទុក្ខទោសដល់អនីតិជន ។

15. សិទ្ធិក្នុងការជូនដំណឹងជាមុនដោយមានហេតុផលស្តីពីការផ្លាស់ប្តូរសេវា ឬការគិតថ្លៃសេវា ។

16. សិទ្ធិក្នុងការដឹងអំពីមូលហេតុរបស់អ្នកផ្តល់សេវាក្នុងការបញ្ឈប់ការផ្តល់សេវាកម្ម ។

17. សិទ្ធិក្នុងការទទួលបានការជូនដំណឹងមុនយ៉ាងតិចចំនួនដប់ថ្ងៃចំពោះការបញ្ឈប់សេវាដែលធ្វើឡើងដោយអ្នកផ្តល់សេវា លើកលែងតែក្នុងករណី៖
(i) អតិថិជនជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិដែលធ្វើឲ្យមានការកែប្រែសារៈសំខាន់នៃលក្ខន្តិកៈគម្រោងសេវា ដែលធ្វើឡើងជាមួយនឹងភាគីផ្តល់សេវាថែទាំនៅផ្ទះ ។
(ii) អតិថិជន បុគ្គលដែលស្នាក់នៅជាមួយអតិថិជន ឬអ្នកផ្សេងទៀតដែលរំលោភ ឬធ្វើឲ្យបរិយាកាសធ្វើការអសុវត្ថិភាព សម្រាប់បុគ្គលដែលផ្តល់សេវាថែទាំនៅផ្ទះ ឬ
(iii) ការផ្លាស់ប្តូរកម្រិតខ្លាំងឬបន្ទាន់ចំពោះលក្ខខណ្ឌធ្វើឡើងដោយភាគីអតិថិជន ដែលធ្វើឲ្យមានតម្រូវការផ្នែកសេវាកម្មលើសពីកម្រិតនៃគម្រោងសេវាកម្មបច្ចុប្បន្ន ហើយដែលមិនអាចធ្វើឲ្យភាគីផ្តល់សេវាថែទាំនៅផ្ទះទទួលយកមកធ្វើបាន ។

18. សិទ្ធិក្នុងការផ្ទេរផ្លាស់ដោយមានការសម្របសម្រួលនៅពេលណាដែលនឹងមានការផ្លាស់ប្តូរអ្នកផ្តល់សេវាកម្ម ។

19. សិទ្ធិក្នុងការតវ៉ាទៅលើសេវាកម្មដែលបានផ្តល់ជូន ឬការខកខានមិនអាចផ្តល់ជូន ក៏ដូចជាកង្វះខាតភាពគួរសម ឬខ្វះការគោរពដល់អតិថិជន ឬដល់កម្មសិទ្ធិនានារបស់អតិថិជន ។

20. សិទ្ធិក្នុងការដឹងអំពីរបៀបទាក់ទងទៅកាន់បុគ្គលម្នាក់ៗដែលទាក់ទងជាមួយនឹងការផ្តល់សេវាថែទាំនៅផ្ទះដែលជាអ្នកទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហានានា ក៏ដូចជាសិទ្ធិក្នុងការឲ្យអ្នកផ្តល់សេវាថែទាំនៅផ្ទះធ្វើការស៊ើបអង្កេត និងខំប្រឹងប្រែងដោះស្រាយភាពអយុត្តិធម៌ ឬដោះស្រាយបណ្តឹង ។

21. សិទ្ធិក្នុងការដឹងនូវឈ្មោះ និងអាសយដ្ឋាននៃភ្នាក់ងាររដ្ឋ ឬប្រទេសដើម្បីទាក់ទងសម្រាប់ព័ត៌មានបន្ថែម ឬសម្រាប់ជំនួយការ ។

22. សិទ្ធិក្នុងការនិយាយបញ្ជាក់អះអាងអំពីសិទ្ធិទាំងនេះដោយផ្ទាល់ខ្លួន ឬមានសិទ្ធិក្នុងការប្រើអ្នកតំណាងឲ្យនិយាយបញ្ជាក់អះអាង ឬនិយាយបញ្ជាក់អះអាងដោយនរណាម្នាក់ក្នុងនាមអតិថិជន ដោយគ្មានការសងសឹក ។

**ប្រសិនបើលោកអ្នកមានបណ្ដឹងអំពីអ្នកផ្ដល់សេវា ឬបុគ្គលដែលផ្ដល់សេវាថែទាំនៅផ្ទះ លោកអ្នកត្រូវទូរស័ព្ទ សរសេរលិខិតជាលាយលក្ខណ៍អក្សរ ឬអញ្ជើញទៅកាន់ការិយាល័យទទួលបន្ទុកសម្រួលបណ្ដឹងផ្នែកសុខាភិបាលនៃមន្ទីរសុខាភិបាល MINNESOTA ។ លោកអ្នកក៏ត្រូវទាក់ទងទៅកាន់ការិយាល័យនៃមន្ត្រីចាត់តាំងផ្នែកអង្កេតនិងទទួលបណ្ដឹង ផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង ឬទាក់ទងទៅកាន់ការិយាល័យនៃមន្ត្រីចាត់តាំងផ្នែកអង្កេតនិងទទួលបណ្ដឹង ផ្នែកអភិវឌ្ឍន៍អសមត្ថភាព និងសុខភាពផ្លូវចិត្ត**

**ការិយាល័យទទួលបន្ទុកសម្រួលបណ្ដឹងផ្នែកសុខាភិបាល**

**ទូរស័ព្ទ៖** (651) 201-4201 ឬ 1-800-369-7994

**ទូរសារ៖** (651) 281-9796

**គេហទំព័រ៖** http://www.health.state.mn.us/divs/fpc/ohfcinfo/contohfc.htm

**សារអេឡិចត្រូនិក៖** health.ohfc-complaints@state.mn.us

**អាសយដ្ឋានប៉ុស្ដិ៍៖**

មន្ទីរសុខាភិបាល Minnesota

ការិយាល័យទទួលបន្ទុកសម្រួលបណ្ដឹងផ្នែកសុខាភិបាល

ផ្ទះលេខ 85 កន្លែងទីប្រាំពីរភាគខាងកើត បន្ទប់លេខ 300

ប្រអប់សំបុត្រលេខ 64970

ផ្លូវ ផូល (Paul) មីនណេសូតា (Minnesota) 55164-0970

**មន្ត្រីចាត់តាំងផ្នែកអង្កេត និងទទួលបណ្ដឹងផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង**

**ទូរស័ព្ទ៖** (651) 431-2555 ឬ 1-800-657-3591

**ទូរសារ៖** (651) 431-7452

**គេហទំព័រ៖** http://tinyurl.com/Ombudsman-LTC

**សារអេឡិចត្រូនិក៖** mba.ooltc@state.mn.us

**អាសយដ្ឋានប៉ុស្ដិ៍៖**

មន្ត្រីចាត់តាំងផ្នែកអង្កេត និងទទួលបណ្ដឹងផ្នែកការថែទាំនៅផ្ទះ

មន្ត្រីចាត់តាំងផ្នែកអង្កេត និងទទួលបណ្ដឹងផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង

ប្រអប់សំបុត្រលេខ 64971

ផ្លូវ Paul MN 55164-0971

**មន្ត្រីចាត់តាំងផ្នែកអង្កេតនិងទទួលបណ្តឹង ផ្នែកអភិវឌ្ឍន៍អសមត្ថភាព និងសុខភាពផ្លូវចិត្ត**

**ទូរស័ព្ទ៖** 651-757-1800 ឬ 1-800-657-3506

**ទូរសារ៖** 651-797-1950 ឬ 651-296-1021

**គេហទំព័រ៖** http://mn.gov/omhdd/

**សារអេឡិចត្រូនិក៖** ombudsman.mhdd@state.mn.us

**អាសយដ្ឋានប៉ុស្តិ៍៖**

ផ្ទះលេខ121 ភាគខាងកើតកន្លែងទីប្រាំពីរ

បន្ទប់លេខ 420 អាគារមេត្រូការេ (Metro Square Building)

ផ្លូវ ផូល (Paul) រដ្ឋមីនណេសូតា (Minnesota) 55101-2117

**នាមអ្នកទទួលអាជ្ញាប័ណ្ណ៖** ____________________________________________

**ទូរស័ព្ទ៖** ______________________ **សារអេឡិចត្រូនិក៖** ______________________

**អាសយដ្ឋាន៖** ____________________________________________

**នាម/ងារ របស់បុគ្គលដែលជាអ្នកត្រូវទាក់ទងដោយផ្ទាល់ពេលមានបញ្ហាឬមានការតវ៉ា៖**

____________________________________________

សម្រាប់ជាព័ត៌មានតែប៉ុណ្ណោះ ហើយមិនមែនជាការបង្គាប់ឲ្យធ្វើនៅក្នុងអត្ថបទសេចក្តីប្រកាសសិទ្ធិឯកត្តជនស្តីពីការថែទាំនៅផ្ទះឡើយ ។

ច្បាប់ MN ផ្នែក 144A.44

Subd ។ 2. **ការបកស្រាយ និងការអនុវត្តសិទ្ធិ ។**

សិទ្ធិទាំងនេះត្រូវបានបង្កើតឡើងដើម្បីជាប្រយោជន៍ដល់អតិថិជនទាំងឡាយណាដែលទទួលយកនូវសេវាថែទាំនៅផ្ទះ ។

**គ្រប់អ្នកផ្តល់សេវាថែទាំនៅផ្ទះទាំងអស់ ដោយរួមបញ្ចូលទាំងអ្នកផ្តល់សេវាដែលរួចផុតពីអំណាចយុត្តាធិការផ្នែក 144A.471**

**ត្រូវអនុវត្តតាមផ្នែកនេះទាំងអស់ ។** អាណត្តិគាហកៈត្រូវអនុវត្តផ្នែកនេះ

ហើយតម្រូវការនៃសេចក្តីប្រកាសសិទ្ធិឯកត្តជនមានអានុភាពប្រតិសកម្មទៅនឹងអ្នកផ្តល់សេវាថែទាំនៅផ្ទះដែលរួចផុតពីការឲ្យអាជ្ញាប័ណ្ណដូចគ្នាទៅនឹងលក្ខណៈ

សម្រាប់អ្នកទទួលអាជ្ញាប័ណ្ណ ។ អ្នកផ្តល់សេវាថែទាំនៅផ្ទះអាចនឹងមិនស្នើ

ឬតម្រូវឲ្យអតិថិជនប្រគល់សិទ្ធិទាំងនេះជាផ្នូរនៃលក្ខខណ្ឌក្នុងការទទួលយកសេវានោះឡើយ ។ សេចក្តីថ្លែងការស្តីពីសិទ្ធិ មិនអាចជំនួស

ឬបន្ថយសិទ្ធិនិងសេរីភាពដទៃផ្សេងទៀតដែលមានស្រាប់ទាក់ទងទៅនឹងអតិថិជនដែលទទួលសេវាថែទាំនៅផ្ទះបុគ្គលដែលផ្តល់សេវាថែទាំនៅផ្ទះ

ឬអ្នកផ្តល់សេវាដែលមានអាជ្ញាប័ណ្ណស្ថិតនៅក្រោមផ្នែក 144A.43 រហូតដល់ 144A.482 ។